# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧៦១

ចុះថ្ងៃទី ០៨_១២_២០០៩

សាលដីកា

លេខ : ៤៨ "ខ"

ចុះថ្ងៃទី ១៦_០៦_២០១០

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦_០៦_២០១០ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកជំទាវ [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៧៦១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ដែលមាន:

- **ជនជាប់ចោទឈ្មោះ** [redacted] **ដារ៉ាវុធ** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបររៀនជួសជុលទូរស័ព្ទ កើតនៅភូមិក្រចេះ ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ទីលំនៅមុនពេលចាប់ខ្លួន[redacted] សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ [redacted]" នៅលីវ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី ០១-១១-០៨។

មានលោក [redacted] ហៃ ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> ប្លន់ (ឆក់កាបូប) ប្រព្រឹត្តនៅសង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted]សុភ័ក្រ្ត ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៨R ផ្លូវលំ ក្រុម៦ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៨១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] **ដារ៉ាវុធ** ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## ៦ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ២០ និង ១០នាទី ជនរងគ្រោះឈ្មោះ [redacted] សុភ័ក្ត្រ បានជិះម៉ូតូឌុបគូដណ្តឹងឈ្មោះ [redacted] សារី តាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ស្រាប់តែមានជនល្មើសឈ្មោះ [redacted] **ដារ៉ាវុធ** និងឈ្មោះ **ឆេះ** ជិះម៉ូតូមួយគ្រឿងឌុបតាមកអែបនឹងម៉ូតូជនរងគ្រោះរួច ហើយធ្វើសកម្មភាពឆក់កាបូបពីជនរងគ្រោះតែម្តង។ ក្រោយពីធ្វើសកម្មភាពឆក់បានហើយ ជនល្មើសក៏បានជិះម៉ូតូគេចខ្លួន ប៉ុន្តែម៉ូតូនោះក៏ទៅប៉ះជាមួយរថយន្តគេបណ្តាលឱ្យដួល ហើយក៏ត្រូវសមត្ថកិច្ចចាប់បានជាក់ស្តែង។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោម:**

១- ផ្តន្ទាទោសលើឈ្មោះ [redacted] **ដារ៉ាវុធ** ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០០៨។

ពីបទ ប្លន់ (ឆក់កាបូប) ប្រព្រឹត្តនៅសង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- ឱ្យឈ្មោះ [redacted] **ដារ៉ាវុធ** ចេញប្រាក់សងសំណងអន្តរាយចំនួន ១.៣០០.០០០រៀល (មួយលានបីសែនរៀល) ឱ្យទៅដើមបណ្តឹងឈ្មោះ [redacted] សុភ័ក្ត្រ។ ដើមបណ្តឹងទាមទារលើសពីនេះបដិសេធចោល។

តាមមាត្រា ១៤, ១៥ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹង ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៨១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ **ហេង ដារ៉ាវុធ** ជាជនជាប់ចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ដារ៉ាវុធ** បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្ត្រ បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

តាមអង្គហេតុ និងអង្គច្បាប់ក្នុងរឿងនេះគឺមានបទល្មើសជាក់ស្តែង និងមានពិរុទ្ធគ្រប់គ្រាន់ ដូច្នេះ មហាអយ្យការសាលាឧទ្ធរណ៍សូមសន្និដ្ឋានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

រឿងនេះកូនក្តីខ្លួនបានឆ្លើយថា ខ្លួនបានជិះម៉ូតូរបស់ពូកម៉ាកគាត់ ហើយមានគ្រោះថ្នាក់ចរាចរ ហើយពូកម៉ាកជាអ្នកឆក់យកទូរស័ព្ទ ខ្លួនពុំបានឆក់ និងពុំបានដឹងទេ។ ចំពោះម៉ូតូគឺម៉ូតូរបស់មិត្តភក្តិខ្លួនដែលជិះនៅពីក្រោយជាអ្នកធ្វើសកម្មភាព។ ហើយតាមអង្គហេតុកូនក្តីខ្លួនមានអាយុទើបតែអាយុ ១៧ឆ្នាំ យោងតាមអង្គច្បាប់ គឺត្រូវមានការគិតគូរដល់កុមារឱ្យបានត្រូវតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ សូមក្រុមប្រឹក្សាមេត្តាពិចារណាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
- ក្រោយពីបានពិភាក្សា រិះគន់ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា៖

១- បណ្តឹងឧទ្ធរណ៍លេខ ៤៨១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted]ដារ៉ាវុធ ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ជនជាប់ចោទជាមួយនិងគូកនបានជិះម៉ូតូធ្វើសកម្មភាពប្លន់ (ឆក់កាបូប) ជនរងគ្រោះឈ្មោះ [redacted] **សុភ័ក្រ**។ លុះឆក់បានកាបូបហើយ ជនជាប់ចោទក៏បង្កើនល្បឿនម៉ូតូ ហើយជ្រុលទៅបុករថយន្តបណ្តាលឱ្យដួល ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបាននាពេលនោះតែម្តង ។

៣- តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ខ្លួន និងឈ្មោះ **ឆេរ** បានជិះម៉ូតូ ដោយខ្លួនជាអ្នកបើកក្នុងល្បឿនធម្មតា លុះដល់ស្ថានីយ៍ប្រេងតេលា **ឆេរ** ឱ្យខ្លួនបង្កើនល្បឿនទៅអែបជនរងគ្រោះដែលជិះម៉ូតូនៅខាងមុខ តែខ្លួនមិនដឹងថា **ឆេរ** បម្រុងធ្វើអីទេ។ លុះខ្លួនទៅផុតម៉ូតូជនរងគ្រោះ ស្រាប់តែឮគេស្រែកថា ចោរៗ តែខ្លួនមិនដឹងថាគេស្រែកដាក់ខ្លួនទេ ។ ពេលម៉ូតូខ្លួនដួលឈ្មោះ **ឆេរ** ស្ទុះលើកម៉ូតូខ្លួនជិះរត់បាត់ ។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ (ឆក់កាបូប) ប្រព្រឹត្តនៅសង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៥- តាមសៀវភៅគ្រួសារ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០១ និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៩ ជនជាប់ចោទកើតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩១។ ដូច្នេះ នៅពេលប្រព្រឹត្តបទល្មើសថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ជនជាប់ចោទទើបតែមានអាយុ ១៧ឆ្នាំ ៦ខែ ២៨ថ្ងៃ នៅក្នុងភាពជាអនីតិជននៅឡើយ ។ ហេតុនេះ

សាលាឧទ្ធរណ៍គួរពិចារណាអំពីកំណត់នៃទណ្ឌកម្មលើជនជាប់ចោទ តាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ និងមាត្រា ១៦០ (១) នៃក្រមព្រហ្មទណ្ឌ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវគួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១ គួរកែប្រែដូចបានយល់ឃើញខាងលើ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៨១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ របស់ជនជាប់ចោទឈ្មោះ ហេង ដារ៉ាវុធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦៤ "ក្រ២" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ ស្តីពីកម្រិតទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ដារ៉ាវុធ ត្រូវកែប្រែជា ២ឆ្នាំ ៦ខែ (ពីរឆ្នាំប្រាំមួយខែ) វិញ តាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ និងមាត្រា ១៦០ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។ ក្រៅពីនេះរក្សាទុកនៅដដែល។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ៣០ ខែ 12 ឆ្នាំ២០១០
ក្រឡាបញ្ជី

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]